# កិច្ចតែងការបង្រៀន

- មុខវិជ្ជា ៖ ជីវៈវិទ្យា
- ថ្នាក់ទី ៖ ៩
- ជំពូកទី៤ ៖ ភ្នាក់ងារបង្ករោគ និងជម្ងឺ
- មេរៀនទី២ ៖ **ជម្ងឺឆ្លង**
- រយៈពេល ៖ ១ម៉ោង(៥០នាទី)
- ម៉ោងទី១

## I- វត្ថុបំណង

- ចំណេះដឹង៖ កំណត់និយមន័យជម្ងឺឆ្លង និងរៀបរាប់ពីរោគសញ្ញា និងរបៀបឆ្លងនៃជម្ងឺឆ្លង តាមរយៈប័ណ្ណពាក្យបានច្បាស់លាស់។
- បំណិន៖ សង្កេត និងកំណត់អត្តសញ្ញាណ នៃជម្ងឺឆ្លងបានត្រឹមត្រូវតាមរយៈ ការពណ៌នាពីរោគសញ្ញា និងការបិទប័ណ្ណពាក្យលើក្ដាខៀន។
- ឥរិយាបថ៖ បណ្ដុះបណ្ដាលស្មារតីសិស្ស អោយមានអនាម័យខ្លួនប្រាណ និងចេះការពារខ្លួនបានត្រឹមត្រូវ កុំអោយឆ្លងជម្ងឺដោយអនុវត្តតាមក្បួនអនាម័យ ក្នុងជីវភាពរស់នៅ និងណែនាំដល់អ្នកដែលរស់នៅជុំវិញ។

## II- សម្ភារៈបង្រៀន និងរៀន

**ឯកសារយោង៖**

+ សៀវភៅពុម្ពថ្នាក់ទី៩ មុខវិជ្ជាជីវៈវិទ្យា របស់ក្រសួងអប់រំ យុវជន និងកីឡា ទំព័រទី២២២ ដល់ទំព័រទី២២៣ ។
+ សៀវភៅណែនាំគ្រូបង្រៀន STEPSAM3 ។

**សម្ភារៈបង្រៀន និងរៀន**

+ ប័ណ្ណពាក្យ

## III- សកម្មភាពបង្រៀន និងរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| <u>ត្រួតពិនិត្យ</u><br>- អនាម័យ<br>-សណ្ដាប់ធ្នាប់<br>-អវត្តមាន ។ | ជំហានទី១ (២ ឬ៣នាទី)<br>**រដ្ឋបាលថ្នាក់** | ប្រធាន ឬអនុប្រធានថ្នាក់ ជួយសម្របសម្រួលឡើងរាយការណ៍ ពីអវត្តមានសិស្ស។ |

| | | |
|---|---|---|
| - តើជម្ងឺភាគច្រើន បង្កឡើងពីអ្វី?<br><br>- បើសិនជាមានអ្នក កើតជម្ងឺផ្តាសាយអង្គុយក្បែរយើង។ តើយើងអាចកើតឆ្លងជម្ងឺផ្តាសាយដែរឬទេ? មូលហេតុអ្វី? | ជំហានទី២ (១០នាទី)<br>**រំឭកមេរៀនចាស់** | - ជម្ងឺភាគច្រើន បង្កឡើងពីវីរុស និងបាក់តេរី។<br>- បើសិនជាមានអ្នកកើតជម្ងឺផ្តាសាយអង្គុយក្បែរ នោះខ្ញុំអាចឆ្លងជម្ងឺផ្តាយពីអ្នកអង្គុយក្បែរនោះ ដោយសារជម្ងឺផ្តាសាយ ជាជម្ងឺឆ្លង។ |
| - គ្រូសរសេរចំណងជើងមេរៀន ដាក់នៅលើក្តាខៀន ។<br>- ថ្ងៃនេះយើងនឹងសិក្សា អំពីមេរៀនថ្មីមួយទៀត។ | **ជំហានទី៣៖ មេរៀនថ្មី (៣០នាទី)**<br>**ជំពូកទី៤ ៖ ភ្នាក់ងារ និងជម្ងឺឆ្លង**<br>**មេរៀនទី២៖ ជម្ងឺឆ្លង**<br>**១. <u>ជម្ងឺឆ្លង</u>**<br>**១.១. រោគសញ្ញា នៃជម្ងឺឆ្លងមួយចំនួន**<br>**+ សំណួគន្លឹះ** | -សិស្សកត់ចំណងជើងមេរៀន ចូលទៅក្នុងសៀវភៅ។<br>- សិស្សស្តាប់។ |
| តើជម្ងឺអ្វីខ្លះជាជម្ងឺឆ្លង? ហើយជម្ងឺឆ្លងទាំងនោះ ឆ្លងតាមរបៀបណា? | | |
| - ចូរប្អូនរៀបរាប់ពីឈ្មោះជម្ងឺឆ្លង ដោយសរសេរដាក់លើក្តាឆ្នួន។<br>- ដើម្បីផ្ទៀងផ្ទាត់ ការទស្សន៍ទាយរបស់ប្អូនថា ត្រឹមត្រូវ ឬមិនត្រឹមត្រូវនោះ តើយើងត្រូវធ្វើដូចម្តេច?<br>- បិទតារាងរោគសញ្ញា នៃជម្ងឺឆ្លងមួយចំនួន ដែលមិនមានដាក់ឈ្មោះនៃប្រភេទជម្ងឺឆ្លង និងរបៀបឆ្លង ដោយអោយ សិស្សផ្ទៀងផ្ទាត់ចម្លើយនៅលើក្តាខៀន ទៅនឹងប័ណ្ណពាក្យរបស់ពួកគេ។<br>- បែងចែកសិស្សជា ៥ក្រុម រួចចែកសន្លឹកកិច្ចការ អោយក្រុមនីមួយៗ។<br>- បន្ទាប់មក ចែកប័ណ្ណពាក្យ: | + **<u>សម្មតិកម្ម</u>**<br><br>+ **<u>សកម្មភាព</u>**<br>(see table below) | - សិស្សរៀបរាប់ពីឈ្មោះជម្ងឺឆ្លង ដោយសរសេរដាក់លើក្តាឆ្នួន។<br><br>- សិស្សផ្ទៀងផ្ទាត់ចម្លើយ លើក្តាខៀន ជាមួយប័ណ្ណពាក្យរបស់ពួកគេ។<br><br>- សិស្សមើលសន្លឹកកិច្ចការ រួចបំពេញក្នុងផ្នែកផ្សេងៗនៃតារាង។<br>- សិស្សឡើងមកដាក់ឈ្មោះ ផ្នែក |

| ជម្ងឺ | របៀបឆ្លង | រោគសញ្ញា |
|---|---|---|
| ............ ............ | ............ ............ | ក្រហមលើស្បែក ឡើងកំដៅ តឹងច្រមុះ និងឈឺបំពង់ក |
| ............ ............ | ............ ............ | ស្នាមកន្ទួលលើស្បែក |
| ............ ............ | ............ ............ | គ្រុនរងារ ក្អួតចង្អោរ ហើមថ្លើម ស្បែកលឿង និងឈឺសន្លាក់ |
| ............ ............ | ............ ............ | ឈឺក្បាល តឹងកញ្ចឹងក និងសាចក់ដុំកម្រើកលែងរួច |
| ............ ............ | ............ ............ | ឈឺក្បាល ឈឺសាច់ដុំ ចប់ដង្ហើម ក្តៅលើសពី ៣៨អង្សាសេ (ក្រោយពីប៉ះពាល់បក្សីឈឺ ឬងាប់រយៈពេល ៧ថ្ងៃ) |

កញ្ច្រឹល, អុតស្វាយ, រលាកថ្លើម, គ្រុនស្វិតដៃជើង, ផ្តាសាយបក្សី, ចរន្តខ្យល់, ឆ្លងតាមឈាម ចំណីអាហារ ទឹក ការរួមភេទ, ចំណីអាហារ និងទឹក, ការប៉ះពាល់ ឬបរិភោគបក្សីឈឺ ឬងាប់ ទៅកន្លែងបក្សីឈឺឬងាប់ មុជទឹកត្រពាំង ឬស្រះដែលមានបក្សីហែលលេង។

ផ្សេងៗនៃប្រភេទជម្ងឺ និងរបៀបឆ្លង រួចផ្ទៀងផ្ទាត់ការទស្សន៍ទាយ របស់ពួកគេ។

+ **លទ្ធផល**

| ជម្ងឺ | របៀបឆ្លង | រោគសញ្ញា |
|---|---|---|
| កញ្ច្រឹល | ចរន្តខ្យល់ | ក្រហមលើស្បែក ឡើងកំដៅ តឹងច្រមុះ និងឈឺបំពង់ក |
| អុតស្វាយ | ចរន្តខ្យល់ | ស្នាមកន្ទួលលើស្បែក |
| រលាកថ្លើម | ឆ្លងតាមឈាម ចំណីអាហារ ទឹក ការរួមភេទ | គ្រុនរងារ ក្អួតចង្អោរ ហើមថ្លើម ស្បែកលឿង និងឈឺសន្លាក់ |
| គ្រុនស្វិតដៃជើង | ចំណីអាហារ និងទឹក | ឈឺក្បាល តឹងកញ្ចឹងក និងសាចក់ដុំកម្រើកលែងរួច |
| ផ្តាសាយបក្សី | ការប៉ះពាល់ ឬបរិភោគសត្វបក្សីឈឺ ឬងាប់ ទៅកន្លែង ដែលមានបក្សីឈឺឬងាប់ មុជទឹកត្រពាំង ឬស្រះ ដែលមានបក្សីហែលលេង | ឈឺក្បាល ឈឺសាច់ដុំ ថប់ដង្ហើម ក្តៅលើសពី ៣៨អង្សាសេ (ក្រោយពីប៉ះពាល់បក្សីឈឺ ឬងាប់រយៈពេល ៧ថ្ងៃ) |

- ចូរប្អូនពណ៌នាពីរោគសញ្ញា និងរបៀបឆ្លង ដែលអ្នកបានសង្កេត។

+ **សន្និដ្ឋាន**

- ជម្ងឺកញ្ច្រឹល ឆ្លងតាមចរន្តខ្យល់ ហើយមានរោគសញ្ញាដូចជា ក្រហមលើស្បែក ឡើងកម្តៅ តឹងច្រមុះ និងឈឺបំពង់ក។
- ជម្ងឺអុតស្វាយ ឆ្លងតាមចរន្តខ្យល់ ហើយមានរោគសញ្ញា ស្នាមកន្ទួលនៅលើស្បែក។
- ជម្ងឺរលាកថ្លើម ឆ្លងតាមឈាម ចំណីអាហារ ទឹក ការរួមភេទ ហើយមានរោគសញ្ញាដូចជា គ្រុនរងារ ក្អួតចង្អោរ ហើម

| | | |
|---|---|---|
| | ថ្លើម ស្បែកលឿង ឈឺសន្លាក់។<br>- ជម្ងឺគ្រុនស្វិតដៃជើង ឆ្លងតាមចំណីអាហារ និងទឹក ហើយមានរោគសញ្ញាដូចជា ឈឺក្បាល តឹងកញ្ចឹងក និងសាច់ដុំកម្រើកលែងរួច។<br>- ជម្ងឺផ្ដាយសាយបក្សី ឆ្លងតាមការប៉ះពាល់ ឬបរិភោគបក្សីឈឺឬងាប់ ទៅកន្លែងដែលមានបក្សីឈឺឬងាប់ មុជទឹកត្រពាំង ឬស្រះ ដែលមានបក្សីឈឺឬងាប់។ វាមមានរោគសញ្ញាដូចជា ឈឺក្បាល ឈឺសាច់ដុំ ថប់ដង្ហើម ក្ដៅលើសពី ៣៨អង្សាសេ (ក្រោយពីការប៉ះពាល់បក្សីឈឺឬងាប់ រយៈពេល ៧ថ្ងៃ)។ | |
| - តើជម្ងឺកញ្ច្រឹល និងជម្ងឺគ្រុនស្វិតដៃជើង មានរបៀបឆ្លង និងរោគសញ្ញាដូចម្ដេច? | **ជំហានទី៤៖ ពង្រឹងចំណេះដឹង (៥នាទី)**<br>- ជម្ងឺកញ្ច្រឹល ឆ្លងតាមចរន្តខ្យល់ ហើយមានរោគសញ្ញាដូចជា ក្រហមលើស្បែក ឡើងកម្ដៅ តឹងច្រមុះ និងឈឺបំពង់ក។<br>- ជម្ងឺគ្រុនស្វិតដៃជើង ឆ្លងតាមចំណីអាហារ និងទឹក ហើយមានរោគសញ្ញាដូចជា ឈឺក្បាល តឹងកញ្ចឹងក និងសាច់ដុំកម្រើកលែងរួច។ | - សិស្សឆ្លើយ |
| - ពេលប្អូនត្រលប់ទៅផ្ទះវិញ ប្អូនត្រូវអានមេរៀន នៅចំណុចបន្តបន្ទាប់ និងអានមេរៀនដែលយើងបានរៀនរួចសារឡើងវិញ។ | ជំហានទី៥ (៣នាទី)<br>**កិច្ចការផ្ទះ** | -សិស្សស្ដាប់ ហើយអនុវត្តន៍តាមការណែនាំរបស់គ្រូបង្រៀន។ |

# សន្លឹកកិច្ចការ

- តើជម្ងឺឆ្លង មានជម្ងឺអ្វីខ្លះ?

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

## ១. សំណួគន្លឹះ

| តើជម្ងឺអ្វីខ្លះ ជាជម្ងឺឆ្លង? ហើយជម្ងឺទាំងនោះ ឆ្លងតាមរបៀបណា? |
|---|

## ២. សម្មតិកម្ម

ជម្ងឺឆ្លងនិងរបៀបនៃជម្ងឺឆ្លងមានរោគសញ្ញា .......................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

## ៣. សកម្មភាព

ចែកប័ណ្ណពាក្យ ដើម្បីឡើងបិទក្នុងលើតារាង លើក្ដាខៀន

| ជម្ងឺ | របៀបឆ្លង | រោគសញ្ញា |
|---|---|---|
| | | ក្រហមលើស្បែក ឡើងកំដៅ តឹងច្រមុះ និងឈឺបំពង់ក |
| | | ស្នាមកន្ទួលលើស្បែក |
| | | គ្រុនរងារ ក្អួតចង្អោរ ហើមថ្លើម ស្បែក លឿង និងឈឺសន្លាក់ |
| | | ឈឺក្បាល តឹងកញ្ចឹងក និងសាចក់ដុំក កម្រើកលែងរួច |
| | | ឈឺក្បាល ឈឺសាច់ដុំ ចប់ដង្ហើម ក្ដៅលើសពី ៣៨អង្សាសេ (ក្រោយពីប៉ះ ពាល់បក្សីឈឺ ឬងាប់រយៈពេល ៧ថ្ងៃ) |

## ៤. លទ្ធផល

ចូរគូសតារាង ហើយបំពេញអោយបានត្រឹមត្រូវ.......................................................................................

.......................................................................................................................................................

## ៥. សេចក្ដីសន្និដ្ឋាន

ចូរប្អូននិយាយពីជម្ងឺ និងរបៀបចម្លង ដែលបានបំពេញនៅក្នុងតារាងខាងលើ...........................................................

.......................................................................................................................................................

.......................................................................................................................................................